មកពីគណៈប្រធានទីមួយ



ដោយប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# ទ្រង់មានព្រះជន្មរស់ឡើងវិញ !

**ការមានព្រះជន្មរស់ឡើងវិញ** របស់ព្រះយេស៊ូវគ្រីស្ទផ្ដល់ក្ដីសង្ឃឹមដល់យើង ។ វាបានផ្ដល់ក្ដីសង្ឃឹមដល់ខ្ញុំនៅថ្ងៃនៃរដូវក្ដៅឆ្នាំ ១៩៦៩ នោះ ពេលម្ដាយខ្ញុំបានទទួលមរណភាព ។ ខ្ញុំសោកសៅដោយសារខ្ញុំបានបែកពីគាត់ជាបណ្ដោះអាសន្ន ។

ប៉ុន្តែខ្ញុំមានអារម្មណ៍រីករាយ ពេលព្រះវិញ្ញាណបរិសុទ្ធបានប្រាប់ខ្ញុំថា ការរស់ឡើងវិញគឺមានពិត ។ ខ្ញុំអាចស្រមៃឃើញថាវានឹងទៅជាយ៉ាងណា ដើម្បីជួបម្ដាយខ្ញុំ និងមនុស្សជាទីស្រឡាញ់ផ្សេងទៀតជាថ្មីម្ដងទៀតនៅថ្ងៃមួយ ។

ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ។ ដោយសារទ្រង់ បុត្រាបុត្រីទាំងអស់របស់ព្រះវរបិតាសួគ៌ ដែលបានកើតនៅក្នុងពិភពលោកនេះ នឹងបានរស់ឡើងវិញក្នុងរូបកាយមួយដែលមិនចេះស្លាប់ ។●

**ការមានព្រះជន្មរស់ឡើងវិញ** ៖ ពេលដែលព្រះវិញ្ញាណរបស់ព្រះយេស៊ូវបានត្រឡប់ចូលមកក្នុងរូបកាយរបស់ទ្រង់ បន្ទាប់ពីទ្រង់បានសុគត ។ ដោយសារព្រះយេស៊ូវ មនុស្សគ្រប់គ្នាដែលបានស្លាប់ទៅនឹងរស់ឡើងវិញផងដែរ ។

## ដំណើររឿងនៃបុណ្យអ៊ីស្ទើរ

សូមកាត់យកកាតទាំងឡាយចេញ ហើយបិតវាលើក្រដាស ។ ចោះប្រហោង ហើយប្រើខ្សែចងវាជាមួយគ្នា ។ ឥឡូវនេះ អ្នកមានសៀវភៅរឿងបុណ្យអ៊ីស្ទើរមួយហើយ !

កែសម្រួលចេញពី « He Is Risen » *Ensign ឬ Liahona ខែ មេសា ឆ្នាំ២០១៣ ទំព័រ ៤–៥ ។*

● សូមមើលសៀវភៅ *ចូរមកតាមខ្ញុំ* សម្រាប់គោលលទ្ធិ និងសេចក្ដីសញ្ញា ២៩ និងបុណ្យអ៊ីស្ទើរ ។

« ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទដ៏មានព្រះជន្មរស់ឡើងវិញ ហើយជាគំរូ និង ជាអ្នកដឹកនាំផ្លូវដ៏ឥតខ្ចោះរបស់យើង ទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច » ។
ប្រធាន ហិនរី ប៊ី អាវរិង



**១.** ព្រះយេស៊ូវគ្រីស្ទបានគង់លើសត្វលាមួយចូលទៅក្នុងទីក្រុងយេរូសាឡិម ។ ប្រជាជនបានសរសើរតម្កើងទ្រង់ ហើយបានដាក់ស្លឹកត្នោតនៅលើដី ។ ( សូមមើល ម៉ាកុស ១១:១–១១ ) ។



**២.** ព្រះយេស៊ូវបានយាងមកឯព្រះវិហារបរិសុទ្ធ ។ ទ្រង់បានព្យាបាលមនុស្សខ្វិន និងខ្វាក់ ។ ( សូមមើល ម៉ាថាយ ២១:១២–១៤ ) ។



**៣.** ពួកសង្ឃដែលច្រណែនបានបង់ថ្លៃដល់សិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ឈ្មោះ យូដាស-អ៊ីស្ការីយ៉ុត ចំនួន ៣០ រៀល ដើម្បីបញ្ជូនទ្រង់ឲ្យពួកគេ ។ ( សូមមើល ម៉ាថាយ ២៦:១៤-១៦ ) ។



**៤.** ព្រះយេស៊ូវបានសោយអាហារបុណ្យរំលងជាមួយពួកសិស្សទ្រង់ ។ ទ្រង់បានប្រទានសាក្រាម៉ង់ដល់ពួកគេ ដើម្បីជួយពួកគេឲ្យចងចាំដល់ទ្រង់ ។ ( សូមមើល ម៉ាថាយ ២៦:១៩–២០, ២៦–២៨ ) ។



**៥.** ព្រះយេស៊ូវបានយាងទៅច្បារគែតសេម៉ានី ដើម្បីអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ។ នៅទីនោះ ទ្រង់បានរងទុក្ខជំនួសអំពើបាបរបស់យើង ។ មនុស្សបានមកទីនោះជាមួយនឹងដាវ ហើយបានចាប់ទ្រង់ ។ ( សូមមើល ម៉ាថាយ ២៦:៣៦–៥០ ) ។



**៦.** ព្រះយេស៊ូវបានរងទុក្ខ ហើយបានសុគតនៅលើឈើឆ្កាង ។ គេបានដាក់ព្រះកាយរបស់ទ្រង់នៅក្នុងផ្នូរមួយ ដោយមានដុំថ្មធំមួយនៅពីមុខមាត់ផ្នូរ ។ ( សូមមើល ម៉ាថាយ ២៧:២៧–៣៥, ៥៧–៦០ ) ។



**៧.** ពួកទេវតាបានរមៀលថ្មនោះចេញ ។ ពួកទេវតាបានប្រាប់ ម៉ារា ម៉ាក់ដាឡា និងស្ត្រីផ្សេងទៀតថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញហើយ ។ ព្រះយេស៊ូវបានបង្ហាញព្រះកាយដល់ពួកស្ត្រីនោះ ហើយពួកគេបានថ្វាយបង្គំទ្រង់ ។ ( សូមមើល ម៉ាថាយ ២៨:១–១០ ) ។



**៨.** ព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះកាយដល់ពួកសិស្សរបស់ទ្រង់ ។ ពួកគេបានប៉ះព្រះកាយដែលបានរស់ឡើងវិញរបស់ទ្រង់ ។ ទ្រង់បានប្រាប់ពួកគេឲ្យបង្រៀនមនុស្សគ្រប់គ្នាអំពីដំណឹងល្អរបស់ទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ដូច្នេះយើងនឹងរស់ឡើងវិញផងដែរ ! ( សូមមើល លូកា ២៤:៣៦–៤៣; ម៉ាថាយ ២៨:១៦–២០ ) ។